សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសេរីភាព និងការតស៊ូមតិ

NGO Alliance for Freedom & Advocacy (NAFA)

No: 31F, Street 255, Sangkat Boeung Salang, Khan Toulkok

Phnom Penh, Cambodia, Tel: (855) 12 525 552 Email: nafa@online.com.kh


សហរដ្ឋអាមេរិក ថ្ងៃទី១០ សីហា ឆ្នាំ២០០៦


NAFA is an Alliance of

Bright Society (BS)
Khmer Peace Organization (KPO)
Phnom Neangkangrey Association (PNA)
Association Alliance for Rural Restoration (AARR)
Support Association Farmer (SAF)
Chris Development of Kampuchea (CDK)
Women Association for Community Development (WACD)
Khmer Farmer Development (KFD)
Rural Community Environment Development Organization (RCEDO)
Friend' Pioneer Association (FAP)
Human Resource and Nature Development (HRND)
Health car Aids Prevention Organization (HAPO)
Old Age of Miserable People Health Organization (HOM)
Khmer Association for Development of Countryside Cambodia (KAFDOC)
Community Economic Development (CED)
Cambodian Rights & Justice Protection Organization (CARIPO)
Hoped Children for Development Organization (HCDO)
Local Trade Union (LTU)
Cambodia Sociology Club (CSC)


**ជូន សម្តេច ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា**

សម្តេច ជាទីរាប់អាន

ក្នុងរយៈកាលប៉ុន្មានសប្តាហ៍ថ្មីៗនេះ ខ្ញុំបានទទួលនូវព័ត៌មានជាច្រើន តាមរយៈការិយាល័យរបស់ខ្ញុំប្រចាំនៅក្រុងភ្នំពេញ និងការិយាល័យបណ្តាញនៅតាមខេត្តក្រុងនានា ព្រមទាំងតាមរយៈសារព័ត៌មាន នៃកាសែតបរទេស ដែលបានរាយការណ៍ពីស្ថានភាព និងព្រឹត្តិការនានាក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមបញ្ហាទាំងនោះ មានបញ្ហាមួយដែលខ្ញុំមានការចាប់អារម្មណ៍ជាងគេគឺៈ

១. រដ្ឋាភិបាលរបស់សម្តេច បានប្រើ កងកំលាំងប្រដាប់អាវុធ មានទាហាន ប៉ូលីស និងរួមទាំងកងអាវុធហត្ថផងនោះបានធ្វើការបង្ក្រាបយ៉ាងសាហាវ និងហាក់ដូចជាគ្មានមនុស្សធម៌ ទៅលើប្រជារាស្ត្រស្លូតត្រង់ ដែលបានបាត់បង់ដីធ្លី ហើយដែលបាននិងកំពុងធ្វើការតវ៉ា ដើម្បីសុំអោយរដ្ឋាភិបាលជួយដោះស្រាយ ព្រមទាំងការប្រើកំលាំងប្រដាប់អាវុធដូចរាបរាប់ខាងលើ បណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋានប្រៀបដូចជាសត្វធាតុ ដើម្បីយកដីលក់អោយឈ្មួញ។

២. ការរសំរេចចិត្តរបស់គណរដ្ឋមន្ត្រី របស់សម្តេច ធ្វើការបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម ដោយឯកត្តោភាគី ដោយមិនបានធ្វើប្រជាមតិជាមួយប្រជារាស្ត្រ។ នេះជាកំហុសមួយធ្ងន់ណាស់ចំពោះមុខប្រវត្តិសាស្ត្រ ដែលមានន័យស្មើនិងអំពើរក្បត់ជាតិ ក្បត់មាតុភូមិ ព្រោះថាសូម្បីប្រទេសអាមេរិក ថ្វីបើប្រធានាធិបតេយ្យជ្រើសចេញពីការបោះឆ្នោត តែទាក់ទងការងារដែលទាក់ទងអាយុជីវិតរបស់ប្រទេសជាតិគេ ក៏គេធ្វើប្រជាមតិជាមួយប្រជាពលរដ្ឋ មុនធ្វើការសំរេចដែរ។ មួយទៀតទាក់ទងជាមួយនឹងគមរោងចុះហត្ថលេខាជាមួយប្រទេសសៀម លើកិច្ចព្រមព្រាងរុករកកំណប់ប្រេងកាត ក្នុងដែនសមុទ្រខ្មែរ ដែលកំណប់នេះជារបស់ខ្មែរសោះ តើមានមូលហេតុអីដែលត្រូវចែកចាយអោយសៀម?

៣. ការកក្រើកឡើងនៃអំពើរពុករលួយនៃមន្ត្រីរដ្ឋាភិបាល របស់សម្តេច តាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម ដែលទឹកប្រាក់ពុករលួយនេះមានរហូតរាប់លានដុល្លាអាមេរិក ក្នុស្ថានភាពដែលប្រទេសកំពុងជំពាក់បំណុលបរទេសរាបពាន់លានដុល្លា ជាឧទាហរណ៏ សូម្បីតែលោក ឧត្តមសេនីយ៏

ហេង ពៅ ទីប្រឹក្សារបស់សម្តេច និងជាមន្ត្រីមេប៉ូលីសថ្នាក់ក្រុងមួយសោះ មានប្រាក់សល់ក្នុងធនាគារហូតដល់១លានដុល្លា និងប្រាក់សុទ្ធដល់៣០ម៉ឺនដុល្លា នេះមិនរាប់បញ្ចូលជាមួយនូវទ្រព្យសម្បត្តិអចលនៈវត្ថុផ្សេងទៀតផង។ ចុះទម្រាំមន្ត្រីរបស់សម្តេចផ្សេងទៀត ដែលមានឋានៈធំជាងលោក ហេង ពៅ ជាពិសេសមាន លោក សុខ អាន លោក ហុក ឡង់ឌី លោក ម៉ឹង សំផន លោក យឹម ឆៃ លី ដែលជាដន្លងរបស់សម្តេច? ណិងបងប្អូនកូនចៅ ព្រមទាំងមិត្តភក្តរបស់សម្តេច តើមានប្រាក់ប៉ុន្មានសិបលានដុល្លា ពីអំពើរពុករលួយ?

ខ្ញុំយល់ឃើញថា ទំនាស់ និងវិបត្តិដីធ្លី ដែលកើតឡើងនាពេលនេះ វាគឺជាលទ្ធផលដែល រដ្ឋាភិបាលនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច បានរួមគ្នាបង្កើតអោយមាន តាមរយៈការបើកដៃអោយមន្ត្រីយោធា មន្ត្រីស៊ីវិល ក្រុមសាច់ញាត្តិ និងក្រុមអ្នកជំនួញដែលស្និទ្ធជាមួយខ្លួន ធ្វើការរំលោភយកដីពីរាស្ត្រក្រីក្រ និងបោកបញ្ឆោតរាស្ត្រក្រីក្រអោយកាប់ឆ្ការដីអោយខ្លួន ហើយក្រោយមករឹបអូសយកទាំងបំពាន ដោយអាងថាខ្លួនលុយ មានអំណាច និងមានបង្អែកនៅពីក្រោយខ្នង។ ដូច្នោះទំនាស់ដីធ្លីដែលកើតមានឡើងនេះ មិនមែនបណ្តាលមកពីប្រជារាស្ត្រស្លូតត្រង់នោះទេ តែការបង្ក្រាបដោយប្រើអាវុធ ឬកាំភ្លើងបាញ់បោះទៅលើប្រជារាស្ត្រ វាជាអំពើរអមនុស្សធមិ គ្មានសីលធមិ និងគ្មានសិល្បៈក្នុងការដឹកនាំ។ នៅពេលដែលខ្ញុំបានលឺសំរែកប្រជារាស្ត្ររងគ្រោះ ដែលស្រែកតាមរលកធាតុអាកាស់ របស់វិទ្យុបរទេស ធ្វើអោយខ្ញុំនឹកឃើញដល់ប្រជាបាតុករ ដែលស្រែកដោយការឈឺចាប់ ព្រោះរងការបាញ់ប្រហាពីសំណាក់ ក្រុមប្រដាប់អាវុធដែលគាំទ្រ សម្តេច កាលពីឆ្នាំ១៩៩៨ ដែលក្នុងពេលនោះខ្លួនខ្ញុំជាសមាជិកអ្នកដឹកនាំម្នាក់ នៃចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ បានកំពុងនៅក្នុងចំណោមជនរងគ្រោះទាំងនោះដែរ។ រូបភាពទាំងនោះវា បានជិតជាប់ក្នុងអារម្មណ៍របស់ខ្ញុំជានិច្ច បើទោះបីជាខ្ញុំទៅដល់ទីណាក៏ដោយ តែអ្វីដែលមិននឹកស្មាននោះគឺថា រូបភាពនៃអំពើហឹង្សាដូចគ្នានេះ និងមធ្យោបាយបង្ក្រាបដូចគ្នា ដែលបញ្ជាចេញពីអ្នកទទួលខុសត្រូវ តែម្នាក់ដូចគ្នា តើប្រជាពលរដ្ឋខ្មែរចំនួន១១លាននាក់ ពិតជាធ្វើអោយសម្តេច ពិបាកគ្រប់គ្រងណាស់ ឬមួយសម្តេចគ្មានលទ្ធភាពគ្រប់គ្រង និងបែងចែកដីអោយប្រជាពលរដ្ឋធ្វើកសិកម្ម និងធ្វើលំនៅដ្ឋានដើម្បីរស់ទេ? ទាក់ទងនិងចំនុចទី២ ខាងលើ ខ្ញុំយល់ថា ការសំរេចបោះបង្គោលព្រំដែនជាមួយប្រទេសយួន មិនមែនជាបញ្ហាដែលត្រូវធ្វើដោយបន្ទាន់នាពេលនេះ ដោយគ្មានការចូករួមពីសំណាក់ក្រុមអ្នកជំនាញឯកទេស និងក្រុមអ្នករិះគន់នោះទេ បញ្ហានេះត្រូវតែធ្វើឡើងដោយប្រុងប្រយ័ត្ន តែបញ្ហាចំពោះមុខដែលត្រូវធ្វើនោះ គឺសម្តេច ត្រូវតែបង្វែក្រុមយោធា ដែលមាន ទាហាន ប៉ូលិស និងកងអាវុធហត្ថ ទាំងនោះ ព្រមជាមួយនិងអាវុធយុទ្ធភណ្ឌដែលមាន ទៅការពារព្រំដែន ដែលយួន និងសៀមបានរំលោភ មិនមែនប្រើអោយមកបាញ់គំរាម ធ្វើបាបក្រុមអ្នក

ក្រ ដែលគ្មានដីនៅ ហើយជាជនជាតិខ្មែរដូចគ្នាដូចគ្នានោះទេ។ បើគិតពិចារណាទៅ តើទង្វើបែបនេះមានអ្វីខុសប្លែកពីអ្នកគ្រប់គ្រងរបប ប៉ុល ពត ដែលសំលាប់ ធ្វើទារុណកម្ម និងបង្អត់អាហារតែខ្មែរគ្នាឯង? រីឯការចុះកិច្ចព្រមព្រាងជាមួយរដ្ឋាភិបាលសៀមទៀតសោត ក៏ពិតជាមើលមិនឃើញថាមានមូលហេតុអ្វី ដែលត្រូវចែកកំណប់ទ្រព្យក្នុងដែនសមុទ្រខ្មែរ អោយសៀមដែរ ពីព្រោះការដែលសៀម និងយួន ឃុបខិតចុះកិច្ចព្រមព្រាងបិទច្រកសមុទ្រអន្តរជាតិរបស់ខ្មែរ និងរំលោភយកដែនទឹករបស់ខ្មែរ វាជាហេតុផលគ្រប់គ្រាន់ដែលក្នុងនាមសម្តេច ជាប្រមុខរដ្ឋាភិបាល ត្រូវតែធ្វើការតវ៉ា មិនមែនចុះកិច្ចព្រព្រាងបន្ថែមអោយអធិបតេយ្យភាព និងបូរណភាពរបស់ខ្មែរកាន់តែបាត់បង់នោះទេ។ ខ្ញុំសូមរំលឹកសម្តេចថា រដ្ឋាភិបាលរបស់លោក នាយករដ្ឋមន្ត្រី ថាក់ស៊ីន នៃប្រទេសថៃនាពេលនេះ គឺគ្រាន់តែជារដ្ឋាភិបាលចាំផ្ទះ ដូចរដ្ឋាភិបាលចាំផ្ទះរបស់សម្តេចកាលពីក្រោយពេលបោះឆ្នោតថ្មីអញ្ចឹង។

ចំពោះជនពុករលួយ និងអំពើពុករលួយនៅកម្ពុជា ខ្ញុំយល់ថា សម្តេច គួចាប់ផ្តើមពីខ្លួន ក្រុមគ្រួសារ និងសាច់ញាត្តិរបស់សម្តេចជាមុនសិន ហើយប្រកាស់អោយសាធារណៈជនដឹងថា តាំងពីកាន់អំណាចមក តើសម្តេច ក្រុមគ្រួសារ និងសាច់ញាត្តិបាលកេងបន្លំ ប្រព្រឹត្តិអំពើពុករលួយ និងលួចលុយជាតិប៉ុន្មានរយលានដុល្លា ការធ្វើបែបនេះជាសេចក្តីក្លាហានមួយរបស់កូនប្រុស ដូចដែលសម្តេចធ្លាប់បានអោយគេនិពន្ធរឿងពីប្រវត្តិរបស់សម្តេច ហើយដាក់ចំណងជើងថា ***កូនប្រុសក្រោមពន្លឺព្រះច័ន្ទ*** បើមិនដូចនោះទេវាអាចប្រែក្លាយចំណងជើងរឿងនេះអោយទៅជា ***កូនប្រុសចោរម្សៀត*** ? បើធ្វើរបៀបនេះបាន នោះទើបដូចពាក្យដែលខ្ញុំធ្លាប់និយាយថា ត្រូវយកទឹកសមុទ្រទៅរំងាស់ធ្វើអំបិល មិនមែនយកទឹកទន្លេមករំងាស់ធ្វើអំបិលទេ។

ខ្ញុំយល់ថា សំណេរនេះពិតជាពិបាកអានដោយខ្លួងង និងពិបាកស្តាប់ បើមានគេអានអោយស្តាប់តែបើសម្តេចមិនចង់អោយមាន បដិវត្តដីធ្លី ប្រជាចលនាប្រឆាំងការបាត់បង់ទឹកដី និងប្រឆាំងអំពើរពុករលួយទេ គួរតែទទួលយកពិចារណា និងបើមិនអាចធ្វើបានទេ ហើយទទួលស្គាល់ថាខ្លួនគ្មានសមត្ថភាព គួរលាលែងពីអំណាចដោយសន្តិវិធី និងសុំទោសជាសាធារណៈចំពោះរាស្ត្រ អំពីកំហុសឆ្គងដែលខ្លួនបានប្រព្រឹត្តិក្នុងពេលនៅកាន់អំណាច។

ហត្ថលេខា ( ប្រធាន NAFA)

**សួន រដ្ឋា**

**President of NGO Alliance for Freedom & Advocacy (NAFA)**
**Tel: 1 703 967 9717, Email: sournratha@hotmail.com**